# ការវិភាគប្រព័ន្ធក្សេត្រ - បរិស្ថាន
# តំបន់ស្រោចស្រព លំហាច

## I-សេចក្តីផ្តើម

ឯកសារការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានដែលបានរៀបចំនេះគឺជាលទ្ធផលនៃការចុះស្រាវជ្រាវអង្កេតនិងវិភាគអស់ រយៈពេល ៦ ថ្ងៃរបស់ការិយាល័យ និងមន្ត្រីនៃមន្ទីរកសិកម្មខេត្ត, ការិយាល័យកសិកម្មពាក់ព័ន្ធមានស្រុកមបរិបូណ៌/ស្រុកទឹកផុស / ស្រុករលាប្អៀរ / មន្ត្រីមន្ទីរធនធានទឹកនិងឧតុនិយម / មន្ត្រីមន្ទីររៀបចំដែនដីនិងសំណង់ / អភិបាលរងស្រុកមបរិបូណ៌/អភិបាលរងស្រុកទឹកផុស / អភិបាលរងស្រុករលាប្អៀរ / ក្រុមប្រឹក្សាឃុំអញ្ចាញរូង/ក្រុមប្រឹក្សាឃុំក្រាំងស្គារ/ក្រុមប្រឹក្សាឃុំប្រស្នឹប/ក្រុមប្រឹក្សាឃុំផ្សារ មេភូមិ/អនុភូមិ និងកសិករក្នុងភូមិទាំង១១ ក្នុងឃុំព្រមទាំងអ្នកដែលពាក់ព័ន្ធផ្សេងៗទៀតដោយមានការឧបត្ថម្ភគាំទ្រពីគំរោង ស្តារឡើងវិញប្រព័ន្ធស្រោចស្រព និងប្រព័ន្ធដោះទឹកនៅតំបន់ខាងលិចបឹងទន្លេសាប(CP-P11) និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

ឯកសារនេះនឹងផ្តល់នូវទិន្នន័យពិតប្រាកដច្បាស់លាស់ ដោយផ្អែកទៅលើភស្តុតាងជាក់លាក់ និងមានដំណោះស្រាយត្រឹមត្រូវដែលមានសារៈសំខាន់បំផុតសំរាប់រៀបចំធ្វើផែនការអភិវឌ្ឍន៍នៅក្នុង**លំហាច** ដោយបានបញ្ជាក់យ៉ាងច្បាស់អំពីតួនាទីភារៈកិច្ច និងការទទួលខុសត្រូវដោយឡែកពីគ្នានៃអ្នកចូលរួមសហការធ្វើការងារអភិវឌ្ឍន៍នៅក្នុងតំបន់ស្រោចស្រព ។ ជាមួយនេះដែរលទ្ធផលនៃការអនុវត្តន៍ផែនការឃុំនិមួយៗដែលទទួលបានវាឆ្លើយតបនិងតំរូវការពិតប្រាកដរបស់គ្រួសារកសិករភាគច្រើននៅក្នុងឃុំ ហើយការអនុវត្តន៍នោះទទួលបានជោគជ័យនិងមាននិរន្តភាពទៅពេលអនាគតយូរអង្វែង។

### ១.គោលបំណង

ការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាននៅតំបន់ស្រោចស្រព **លំហាច** មានគោលបំណងដើម្បីចងក្រងជាឯកសារមួយដែលមានសារៈសំខាន់សំរាប់តំរូវការរបស់អ្នកពាក់ព័ន្ធទាំងឡាយដូចជាៈក្រុមប្រឹក្សាឃុំទាំង៤ឃុំ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មអង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នទាំងឡាយប្រើប្រាស់ដើម្បីបង្កើននូវការកែលំអ និងកសាងផែនការសំរាប់ការងារ អភិវឌ្ឍន៍វិស័យកសិកម្មនៅក្នុងឃុំក៏ដូចនៅក្នុងតំបន់ស្រោចស្រពទាំងមូលឱ្យទទួលបានជោគជ័យឆ្លើយតបនឹងតំរូវការពិតប្រាកដរបស់គ្រួសារកសិករ និងមាននិរន្តភាព នៅពេលអនាគតយូរអង្វែង។

### ២.ការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានក្នុងគោលបំណងរួមមានៈ

អាស្រ័យហេតុដូចខាងលើការរៀបចំឯកសារនេះនិងសំរេចទិសដៅដូចតទៅៈ

.មានទិន្នន័យជាក់លាក់ច្បាស់លាស់សំរាប់ក្រុមប្រឹក្សាឃុំនិមួយៗ

.មានការកំណត់លក្ខណៈនៃប្រព័ន្ធក្សេត្រ-បរិស្ថានក្នុងក្នុងតំបន់ស្រោចស្រព

.ប្រមូលផ្តុំនូវបញ្ហាទាំងអស់កំណត់បញ្ហាជាអទិភាពកំណត់តំរូវការវិស័យកសិកម្មនិងវិស័យអទិភាពសំរាប់ផ្សព្វផ្សាយនៅក្នុងឃុំ

.វិភាគបញ្ហាវិភាគលក្ខណៈនៃប្រព័ន្ធបង្កើតជាសំនួរគន្លឹះ និងវាយតំលៃបញ្ចូលបច្ចេកវិជ្ជាថ្មីសំរាប់ឃុំ

វិភាគលើឥទ្ធិពលនៃផលប៉ះពាល់លើបរិស្ថាន ភាពក្រីក្រ យេឌ័រ និងបញ្ចូលបទដ្ឋានអនុវត្តន៍បច្ចេកវិជ្ជា(TIP)។

ជាពិសេសលទ្ធផលនៃការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានតំបន់ស្រោចស្រព **លំហាច** ដែលមាននៅក្នុងឯកសារនេះ និងត្រូវបានក្រុម ប្រឹក្សាឃុំយកទៅប្រើប្រាស់ក្នុងការកសាងផែនការអភិវឌ្ឍន៍ឃុំរបស់ខ្លួនប្រកបដោយប្រសិទ្ធិភាពខ្ពស់។

### ៣.ជំហានសំខាន់ៗសម្រាប់ធ្វើការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានថ្នាក់ឃុំបង្ហាញក្នុងតារាងខាង ៖

| ជំហានសម្រាប់ធ្វើការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន | ទីតាំង | ចំនួនថ្ងៃ |
|---|---|---|
| ជំហានទី១ : បង្រៀនទ្រឹស្តី និងការរៀបចំផែនការ | មន្ទីរកសិកម្មខេត្ត | ២ |
| ជំហានទី២ : ប្រមូលទិន្នន័យទី២ និងការរៀបចំ | សាលាឃុំ | ១ |
| ជំហានទី៣ : ការវិភាគទិន្នន័យដំបូង | សាលាឃុំ | ១ |
| ជំហានទី៤ : ការវាយតម្លៃជនបទឆាប់រហ័ស | សាលាឃុំ | ២ |
| ជំហានទី៥ : ការវិភាគប្រព័ន្ធ | មន្ទីរកសិកម្មខេត្ត | ៣ |
| ជំហានទី៦ : ការរៀបចំរបាយការណ៍ និងបញ្ចូលទិន្នន័យ | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម | ១៦ |
| ជំហានទី៧ : បទបង្ហាញដល់ក្រុមប្រឹក្សាឃុំ | សាលាឃុំ | ១ |
| ជំហានទី៨ : រៀបចំផែនការអភិវឌ្ឍន៍ឃុំ | សាលាឃុំ | ១ |

### ៤.សមាសភាពក្រុមការងារ

សមាសភាពក្រុមធ្វើការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានថ្នាក់ឃុំ និងបង្ហាញជូននៅក្នុងតារាង

| លរ | ឈ្មោះ | ជំនាញ | ស្ថាប័ន | ផ្សេងៗ |
|---|---|---|---|---|
| ១ | លោក ឃៀន សុវណ្ណារា | អនុប្រធាននាយកដ្ឋាន | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម | |
| ២ | លោក យុនសូផាន | អនុប្រធានការិ.ប្រព័ន្ធកសិកម្ម | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម | |
| ៣ | ហេង ជូឡុង | មន្ត្រីការិ.ប្រព័ន្ធកសិកម្ម | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម | |
| ៤ | ហេង គឹមស្រៀង | អនុប្រធានមន្ទីកសិកម្ម | មន្ទីរកសិកម្មខេត្ត | |
| ៥ | អែល យឿន | ប្រធានការិ.ផ្សព្វផ្សាយ | មន្ទីរកសិកម្មខេត្ត | |
| ៦ | ស៊ន សុគន្ធា | មន្ត្រីការិ.ស្រុកបរិបូណ៌ | មន្ទីរកសិកម្មខេត្ត | |
| ៧ | ខឹម សំបូរ | អនុប្រធានការិ. | មន្ទីរកសិកម្មខេត្ត | |
| ៨ | អឿន សុអឺន | មន្ត្រីការិ.ក្សេត្រសាស្ត្រ | មន្ទីរកសិកម្មខេត្ត | |
| ៩ | តូច ប៉ូច | មន្ត្រីការិ.ប្រព័ន្ធកសិកម្ម | មន្ទីរកសិកម្មខេត្ត | |
| ១០ | កើត សាវាង | ប្រធានការិ.ស្រុករលាប្អៀរ | មន្ទីរកសិកម្មខេត្ត | |
| ១១ | យ៉ែម អឿរ | ប្រធានការិ.ស្រុកបរិបូណ៌ | មន្ទីរកសិកម្មខេត្ត | |
| ១២ | កែវ សែ | ប្រធានការិ.ស្រុកទឹកផុស | មន្ទីរកសិកម្មខេត្ត | |
| ១៣ | ឈឹម យ៉េត | អភិបាលរងស្រុករលាប្អៀរ | ស្រុករលាប្អៀរ | |
| ១៤ | រឹម ដេត | អភិបាលរងស្រុកបរិបូណ៌ | ស្រុកបរិបូណ៌ | |
| ១៥ | ឃឹម វណ្ណី | អភិបាលរងស្រុកទឹកផុស | ស្រុកទឹកផុស | |
| ១៦ | សុខ វុត្ថា | ប្រធានការិ.រលាប្អៀរ | មន្ទីរធនធានទឹកខេត្ត | |
| ១៧ | កែវ ប៊ុនផេង | មន្ត្រីការិ.សំណង់ | រៀបចំដែនដីនិងសំណង់ខេត្ត | |
| ១៨ | ម៉ូត សៀងហៃ | មន្ត្រីការិ.ស្រុកទឹកផុស | មន្ទីរកសិកម្មខេត្ត | |
| ១៩ | ឈឹម ប៊ុនលៀង | ប្រធានការិ.ស្រុករលាប្អៀរ | មន្ទីរកសិកម្មខេត្ត | |
| ២០ | វ៉ុង ថុន | មេឃុំអញ្ចាញរ៉ូង | មេឃុំអញ្ចាញរ៉ូង | |
| ២១ | ដុម វុន | ក្រុមប្រឹក្សាឃុំអញ្ចាញរ៉ូង | មេឃុំអញ្ចាញរ៉ូង | |

## II-ស្ថានភាពទូទៅរបស់តំបន់ស្រោចស្រព លំហាច

**ប្រវត្តិ:**ជាអាងទឹកចាស់កសាងនៅក្នុងសម័យ **ប៉ុល ពត** បច្ចុប្បន្នមិនអាចប្រើការបានទេទំនប់បាក់ប្រព័ន្ធប្រឡាយបាក់ បែក រាក់ ។តំបន់អាងទឹក **លំហាច** ស្ថិតក្នុងឃុំក្រាំងស្គារស្រុកទឹកផុស ខេត្តកំពង់ឆ្នាំងមានចម្ងាយ៤៧គីឡូម៉ែត្រពីទីរួមខេត្តកំពង់ឆ្នាំងនិ២២គីឡូមែត្រពីផ្លូវជាតិលេខ៥ត្រង់ចំណុចផ្លូវចូល។ តំបន់ស្រោចស្រព **លំហាចមានផ្ទៃអាងសរុប ចំនួន ៨៨៥ហិកតា** តំបន់ស្រោចស្រពនេះ ផ្តល់ផលប្រយោជន៏ដល់វស័យកសិកម្មដល់ប្រជាពលរដ្ឋនៅក្នុងស្រុកចំនួន៣៖

១/ស្រុកទឹកផុសមានចំនួន១ឃុំក្រាំងស្គារភូមិដែលទទួលផលមាន(ភូមិអញ្ចាញ)

២/ស្រុករលាប្អៀចំនួន១ឃុំប្រស្និបភូមិដែលទទួលផលមាន(ភូមិត្រពាំងអំពិល-ភូមិប្រស្និប)

៣/ស្រុកបរិបូណ៌ចំនួន២ឃុំភូមិដែលទទួលផលមាន៤ភូមិគឺ ភូមិអញ្ចាញរូង-ភូមិដំរីកូន-ភូមិអណ្តូងរវៀង-ព្រៃព្រាល ឃុំផ្សារមាន២ភូមិ ភូមិដែលទទួលផលមានមានភូមិថ្មី និងភូមិផ្សារ ។តាមការសិក្សារបស់មន្ទីរ ធន់ធានទឹកតំបន់ស្រោចស្រពលំហាចអាចស្រោចស្រពលើផ្ទៃដីបានចំនួន ៦,៩៥៥ហិកតា និងតំបន់សក្តានុពល២០,៣៧៣ហិកតា នៅក្នុងស្រុក ឃុំ ភូមិ។

<u>**ផែនទីផ្ទៃអាងលំហាច:**</u>



# ផែនទីប្រព័ន្ធស្រោចស្រព



## II-ឧបករណ៍សម្រាប់វាយតម្លៃជនបទយ៉ាងឆាប់រហ័ស

### ១.ឋានានុក្រមតំបន់ស្រោចស្រព



## ៦.ផែនទីបង្ហាញជីជាតិដីក្នុងខេត្ត

# ផែនទីបង្ហាញជីជាតិដីក្នុងខេត្តកំពង់ឆ្នាំង




N

0 4.75 9.5 km

**ផលិតដោយ:**

- ក្រុមការងារប្លង់គោលខេត្ត
- សហការដោយ:

giz

**កំណត់សំគាល់**

- ផ្លូវជាតិ
- ផ្លូវដែក
- ព្រំប្រទល់ខេត្ត
- ព្រំប្រទល់ស្រុក-ក្រុង
- បឹង ឬ ទន្លេ

***ប្រភេទជីជាតិដី***

- ដីមានជីជាតិខ្ពស់
- ដីមានជីជាតិមធ្យម
- ដីមានជីជាតិតិច

**ផែនទីព្រះរាជាណាចក្រកម្ពុជា**



Data source:

Admin. Boundary:
Census 2088, NIS-MoP

Soil Fertility:
FA, DANIDA and DED, 2003